ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# ស្តីពី

# លទ្ធផលការងាររបស់ព្រឹទ្ធសភា

# ប្រចាំខែកញ្ញា ឆ្នាំ២០១៤

នៅក្នុងខែកញ្ញា ឆ្នាំ២០១៤នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចរបស់ខ្លួនដូចតទៅ៖

**១.សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា បាន៖**

-ទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន០១លើក

-បានធ្វើសំណើសុំប្រទានសិទ្ធចំនួន៧២សំណើ និងបានទទួលព្រះរាជសារប្រទានសិទ្ធពីព្រះមហាក្សត្រចំនួន៧២ព្រះរាជសារ និងបានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៧២ព្រះរាជក្រឹត្យ

-ចុះហត្ថលេខាលើលិខិតផ្សេងៗចំនួន១២លិខិត ។

**១.២ ឯកឧត្តម សាយ ឈុំ អនុប្រធានទី១ព្រឹទ្ធសភា បាន៖**

-ទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន០១លើក

-អញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០៣លើក និងកិច្ចប្រជុំពេញអង្គព្រឹទ្ធសភាចំនួន០៤លើក

-អញ្ជើញចុះជួបអាជ្ញាធរសង្កាត់ស្មោ សំណេះសំណាលសាកសួរសុខទុក្ខ និងស្តាប់សភាពការណ៍ក្នុងមូលដ្ឋានរួមមានៈសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ, ការអនុវត្តច្បាប់, ការកែលំអរសេវាសាធារណៈ, ស្ថានភាពនៃការអនុវត្តគោលនយោបាយភូមិ-សង្កាត់មានសុវត្ថិភាព,ការបង្ករបង្កើនផល និងការអភិវឌ្ឍន៍លើវិស័យផ្សេងៗទៀតក្នុងមូលដ្ឋាន

-អញ្ជើញទៅសាកសួរសុខទុក្ខ លោកយាយ **ផ្ទេក ភីរុណ** ជាឥស្សរជន និងជាព្រឹទ្ធាចារ្យដ៏ឧត្តមមួយរូប ដែលបានបូជា កម្លាំងកាយ ចិត្ត ប្រាជ្ញា ដើម្បីបុព្វហេតុប្រទេសជាតិ និងប្រជាជនកម្ពុជា នៅគេហដ្ឋានរបស់លោកយាយ នៅរាជធានីភ្នំពេញ

-អញ្ជើញចុះសួរសុខទុក្ខប្រជាពលរដ្ឋក្រីក្រ ចាស់ជរាគ្មានទីពឹងពាក់ និងគ្រួសារយុទ្ធ

ជនពលី នៅភូមិឡកំបោរ សង្កាត់ស្វាយប៉ាក ខណ្ឌឫស្សីកែវ និងភូមិព្រៃគ្រាយ សង្កាត់ស្ពោ ខណ្ឌពោធិសែនជ័យ រាជធានីភ្នំពេញ និងនៅភូមិថ្មី, ភូមិព្រៃផ្ទីក ក្នុងឃុំសំពៅងលើ ស្រុកអង្គស្នួល ខេត្តកណ្តាល ដោយបានជូនជាសម្ភារៈ និងប្រាក់កាសមួយចំនួនសំរាប់ពួកគាត់ចូលរួមពិធីបុណ្យកាន់បិណ្ឌ

-អញ្ជើញចុះជួបអាជ្ញាធរ ឃុំស្រង់ ពិនិត្យនិងស្តាប់សភាពការណ៍បង្កបង្កើនផល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ជាពិសេសការអនុវត្តគោលនយោបាយ ភូមិឃុំមានសុវត្ថិភាព ក្នុងមូលដ្ឋានឃុំស្រង់ ហើយឯកឧត្តមបានអញ្ជើញពិនិត្យ ទំនប់ស្វាយ ដែលស្ថិតនៅក្នុងភូមិស្វាយ ឃុំស្រង់ ស្រុកគងពិសី ខេត្តកំពង់ស្ពឺផងដែរ។ ម្យ៉ាងទៀតក្នុងឱកាសនោះដែរ ឯកឧត្តមបានអញ្ជើញនាំយកទេយ្យវត្ថុ សម្ភារៈបរិក្ខារ គ្រឿងឧបភោគបរិភោគ និងបច្ច័យមួយចំនួនប្រគេនព្រះសង្ឃ និងជូនលោកតា លោកយាយ នៅវត្តភ្នំតាមោគ្គ ក្នុងឃុំស្រង់ ស្រុកគងពិសី និងនៅវត្តអម្ពវ័ន(ព្រៃស្វាយ) ក្នុងសង្កាត់សុព័រទេព ក្រុងច្បារមន ខេត្តកំពង់ស្ពឺ

-អញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១ របស់អគ្គមហាធម្មពោធិសាល **ជា ស៊ីម** ប្រមុខរដ្ឋស្តីទី នៅគេហដ្ឋានរបស់សម្តេច ក្នុងសង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

-អញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៥ នៅវត្តពោធិឫទ្ធិ(វត្តត្នោត) និងវត្តវិសុទ្ធវង្សា(វត្តកណ្តាលកោះ) ដែលស្ថិតនៅក្នុងឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម

-អញ្ជើញចូលរួមក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី៥ នៅវត្តវាលស្បូវ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និងបានអញ្ជើញពិនិត្យមើលទូក ង ចំនួន២គ្រឿងដែលជាអំណោយឧបត្ថម្ភរបស់ឯកឧត្តមផ្ទាល់ជូនដល់វត្តវាលស្បូវ និងវត្តសាលព្រឹក្សា ឃុំស្នំក្រពើ ស្រុកគងពិសី ខេត្តកំពង់ស្ពឺ (ដែលបានផ្ញើទុកនៅវត្តវាលស្បូវ) ដើម្បីរៀបចំកែលំអរត្រៀមលក្ខណៈចូលរួមប្រកួត ក្នុងឱកាសប្រារព្ធព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ អកអំបុក នាពេលខាងមុខនេះ

-អញ្ជើញប្រារព្ធពិធីបង្សុកូលឧទ្ទិសកុសលដល់ដួងវិញ្ញាណក្ខន្ធសម្តេចព្រះមង្គលទេពាចារ្យ **អ៊ុម ស៊ុម** ដែលជាព្រះមហាថេរពហុសូត្រមួយព្រះអង្គ ដែលមានចំណេះដឹង និងបទពិសោធន៍ចាស់ទុំក្នុងផ្លូវព្រះពុទ្ធសាសនា នៅកុដិលេខ១ វត្តមហាមន្ត្រី រាជធានីភ្នំពេញ

-អញ្ជើញចូលរួមជាកិត្តិយសជូនដំណើរ សម្តេចអគ្គមហាធម្មពោធិសាល **ជា ស៊ីម** អញ្ជើញទៅពិនិត្យសុខភាព នៅប្រទេសវៀតណាម

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១០៣ច្បាប់ ។

**១.៣ ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា ឯកឧត្តម ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

-អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក និងកិច្ចប្រជុំពេញ

អង្គព្រឹទ្ធសភាចំនួន០២លើក

-អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខ និងចែកអំណោយដល់ប្រជាពលរដ្ឋក្រីក្រ ចាស់ជរា និងជនពិការ ចំនួន២០គ្រួសារ ក្នុងស្រុករតនមណ្ឌល ខេត្តបាត់ដំបង

-អញ្ជើញជាអធិបតីថ្លែងសុន្ទរកថាបើកវេទិកាថ្នាក់ខេត្តស្តីពី "ការស្វែងយល់អំពីការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយេនឌ័រ" នៅខេត្តប៉ៃលិន

-អញ្ជើញជាអធិបតីថ្លែងសុន្ទរកថាបើកវេទិកាថ្នាក់ខេត្តស្តីពី "ព្រឹទ្ធសភា និងការលើកកម្ពស់ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយេនឌ័រ" នៅខេត្តត្បូងឃ្មុំ

-អញ្ជើញជាអធិបតីថ្លែងសុន្ទរកថាបើកវេទិកាថ្នាក់ស្រុកស្តីពី "ព្រឹទ្ធសភា និងការពង្រឹងតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ក្នុងការអភិវឌ្ឍមូលដ្ឋាន និងសមភាពយេនឌ័រ " នៅស្រុកកោះធំ ខេត្តកណ្តាល

-អញ្ជើញជាអធិបតីក្នុងពិធីកាត់ខ្សែបូរសម្ពោធសមិទ្ធផលនានាក្នុងវត្ត នៅស្រុកពញាឮ ខេត្តកណ្តាល

-អញ្ជើញចូលរួមពិធីកាន់បិណ្ឌវេនទី១ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ នៅគេហដ្ឋានសម្តេចប្រធានព្រឹទ្ធសភា និងវេនទី៨ ក្នុងវត្តចំនួន៩ ស្ថិតក្នុងស្រុកទ្រាំង ខេត្តតាកែវ

-អញ្ជើញចូលរួមជាកិត្តិយសពិសាអាហារសាមគ្គីដែលរៀបចំដោយស្ថានឯកអគ្គរដ្ឋទូតសាធារណរដ្ឋប្រជាមានិតចិន

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៥៥ច្បាប់ ។

**២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន ០៣លើក ដើម្បី ៖**

១-ពិនិត្យ និងសម្រេចលើបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំង សមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយតំណាងព្រឹទ្ធសភា ។

២-ពិនិត្យ និងសម្រេចលើសំណើរបស់គណបក្ស សម រង្ស៊ី ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៤ និងសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខៈ ៩៤៦ លគ.គក ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៤ ស្នើរបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការថ្មី (គណៈកម្មការទី១០) និងបំពេញសមាជិកក្នុងគណៈកម្មការទី១,៣,៦,៧,៨ និងគណៈកម្មការទី៩ព្រឹទ្ធសភា ។

៣-ពិនិត្យ និងសម្រេចលើបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងសមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ។

៤-របាយការណ៍ស្តីពី ការពិនិត្យលើសំណើសមាជិកព្រឹទ្ធសភាគណបក្សសម រង្ស៊ី ស្នើចូលជាសមាជិកក្រុមនានារបស់ព្រឹទ្ធសភានីតិកាលទី៣ ។

៥-ពិនិត្យ និងសម្រេចអំពីតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់គណៈកម្មការសង្កេតបោសសម្អាត និងប្រឆាំងអំពើពុករលួយ ។

៦-កំណត់របៀបវារៈ និងកាលបរិច្ឆេទបន្តសម័យប្រជុំលើកទី៥ ព្រឹទ្ធសភា នីតិកាលទី៣។

**៣.សម័យប្រជុំពេញអង្គចំនួន ០៤លើក ដើម្បី ៖**

១-ការបោះឆ្នោតជ្រើសតាំងក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ ០១រូប ។

២-ពិនិត្យ និងអនុម័តសេចក្តីស្នើវិសោធនកម្មប្រការ១៥ នៃបទបញ្ជាផ្ទៃក្នុងព្រឹទ្ធសភា ។

៣-ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មការថ្មី(គណៈកម្មការទី១០) និងបោះ-ឆ្នោត ជ្រើសរើសបំពេញសមាជិកគណៈកម្មការទី១,ទី៣,ទី៦,ទី៧,ទី៨ និងគណៈកម្មការទី៩ ព្រឹទ្ធសភា ។

៣-ការបោះឆ្នោតជ្រើសតាំងសមាជិក ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន ០១រូប។

**៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា**

ក្នុងខែកញ្ញានេះ សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

**៤.១ មុខងារតំណាង**

-បានទទួលពាក្យបណ្តឹងចំនួន០៤ករណី និងបានបញ្ជូនលិខិតទៅស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធដោះស្រាយបានចំនួន០១ករណី

-ប្រជុំក្រុមមិត្តភាពទ្វេភាគីកម្ពុជា-ចិន ស្តីពីការរៀបចំទទួលគណៈប្រតិភូ ខេត្តសានដុងសាធារណរដ្ឋប្រជាមានិតចិន មកចូលរួមពិធីសម្ពោធជើងហោះហើរ "សានដុង-កម្ពុជា "

-ប្រជុំក្រុមសមាជិកប្រចាំភូមិភាគទី៣ស្តីពី ពិនិត្យរបាយការណ៍លទ្ធផលចុះស្រាវជ្រាវព័ត៌មានបន្ថែម នៅស្រុកស្អាង និងស្រុកកោះធំ ព្រមទាំងសម្រេច ជ្រើសរើសទីតាំងរៀបចំវេទិកាថ្នាក់ស្រុក

-ប្រជុំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ស្តីពី "ពិនិត្យ និងអនុម័តលើពាក្យសុំចូលជាសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ របស់ឯកឧត្តម គង់ គាំ

-ប្រជុំស្តីពី " ដំណើរការ សមាហរណកម្មសហគមន៍សន្តិសុខ នយោបាយ និងសហគមន៍សេដ្ឋកិច្ចអាស៊ាន " ដើម្បីត្រៀមចូលរួមមហាសន្និបាតអាយប៉ា AIPA លើកទី៣៥ " នៅទីក្រុងវៀងចន្ទន៍ នៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ

-ប្រជុំពិភាក្សាអំពីគម្រោងរៀបចំសិក្ខាសាលាស្តីពី ការវិវត្តនៃសេចក្តីព្រាងច្បាប់ស្តីពី" ការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង"

-ប្រជុំពិភាក្សាជាមួយលោក Daneil Heilman ទីប្រឹក្សាច្បាប់ជាន់ខ្ពស់អាល្លឺម៉ង់ប្រចាំ

ព្រឹទ្ធសភា ស្ដីពីការត្រៀមរៀបចំសិក្ខាសាលាអបអរសាទរទិវាសិទ្ធមនុស្សអន្តរជាតិ ១០ ធ្នូ ឆ្នាំ២០១៤

-ជួបពិភាក្សាការងារជាមួយលោក **យូរហ៊ិន ឡេមបែក** ប្រធានគម្រោង GIZ គាំទ្រអាជ្ញាធរសវនកម្មជាតិ (GIZ-NAA) និងលោកបណ្ឌិត សុខ ស៊ីណា ទីប្រឹក្សាហិរញ្ញវត្ថុសាធារណៈនៃគម្រោងGIZ-NAAដើម្បីពិនិត្យពិភាក្សាអំពីដំណើរទស្សនកិច្ច នៅប្រទេសអាល្លឺម៉ង់

-អនុញ្ញាតឲ្យលោក Hakan Atasever នាយកប្រតិបត្តិ នៃវិទ្យាស្ថានសន្ទនាមេគង្គ (MDI)និងកញ្ញា Jessical Lee Rehman សាស្ត្រាចារ្យ និងជាបេក្ខនារីបណ្ឌិត នៃសាកលវិទ្យាល័យ California Riverside សហរដ្ឋអាមេរិក ចូលជួបសំណេះសំណាល និងពិភាក្សាការងារ

-អនុញ្ញាតឲ្យគណៈប្រតិភូ ដឹកនាំដោយលោក Jun Arii អគ្គនាយកក្រុមហ៊ុន Mitsubishi ប្រចាំនៅកម្ពុជា ប្រធានគ្រប់គ្រងថវិកាគម្រោងសាងសង់ស្ពានអ្នកលឿង ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ

-អនុញ្ញាតឲ្យគណៈប្រតិភូមួយក្រុមដឹកនាំដោយលោក Lawrance liang អគ្គនាយកធនាគារ Cathay United ចូលជួបសំដែងការគួរសម និងពិភាក្សាការងារ

-បានធ្វើវេទិកាសាធារណៈចំនួន០៥លើក ជាមួយក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រជាពលរដ្ឋនៅខេត្តត្បូងឃ្មុំ,ប៉ៃលិន,ព្រះវិហារ,កណ្ដាល និងខេត្តស្វាយរៀង ស្ដីពីការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ ព្រឹទ្ធសភា និងការពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ ក្នុងការអភិវឌ្ឍមូលដ្ឋាន សេវាសាធារណៈ មូលនិធិថវិកា អភិវឌ្ឍន៍គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងសមភាពយេនឌ័រ

-ចូលរួមសិក្ខាសាលាស្ដីពី " សុខភាពផ្លូវចិត្ត ការអភិវឌ្ឍយុវជន និងបង្ការការធ្វើអត្តឃាត" នៅសណ្ឋាគារ Imperial

-ចូលរួមសិក្ខាសាលាបណ្ដុះបណ្ដាលក្រុមប្រឹក្សាឃុំ-សង្កាត់ស្ដីពី ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

-ចូលរួមស្ដាប់បទឧទ្ទេសនាមរបស់អនុប្រធានគណៈកម្មការកំណែទម្រង់ និងអភិវឌ្ឍន៍ជាតិ នៃសាធារណរដ្ឋប្រជាមានិតចិនស្ដីពី "បទពិសោធន៍របស់ប្រទេសចិនលើការកែទម្រង់ស៊ីជម្រៅគ្រប់ជ្រុងជ្រោយ និងការងារវិមជ្ឈការ និងវិសហមជ្ឈការ"

សមាជិក សមាជិកាព្រឹទ្ធសភា បានចុះទៅតាមបណ្ដាខេត្ត-រាជធានីទូទាំងប្រទេសចំនួន៧៦លើក ដើម្បីចុះជួប និងជួយប្រជាពលរដ្ឋជួបគ្រោះមហន្តរាយខ្យល់ព្យុះ(បាក់ផ្ទះ) និងភ្លើងឆេះផ្ទះ ជួបពិភាក្សាការងារ សាកសួរសុខទុក្ខសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ប្រជាពលរដ្ឋ ពិនិត្យ

ការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្ត គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោលនយោបាយភូមិ-ឃុំ មានសុវត្ថិភាព ស្វែងយល់អំពីស្ថានភាពសិទ្ធិមនុស្ស ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹងអភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យព្រមទាំងបានចូលរួមក្នុងពិធីផ្លូវការ និងពិធីផ្សេងៗ សរុបចំនួន៨៤លើក។

**៤.២ មុខងារព័ត៌មាន / ត្រួតពិនិត្យ**

-គណៈកម្មការទី៨ បានចុះបេសកកម្មទៅខេត្តបាត់ដំបង ដើម្បីទស្សនកិច្ចសិក្សា នៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ។

-គណៈកម្មការទី៩ បានចុះបេសកកម្មនៅខេត្តប៉ៃលិន ដើម្បីជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំខេត្ត និងមន្ទីរដែលជាសមត្ថកិច្ចរបស់គណៈកម្មការ ។

-គណៈកម្មការទី៨ បានជួបសវនាការជាមួយក្រសួងសុខាភិបាល ដើម្បីពិភាក្សាអំពីគម្រោងរៀបចំសិក្ខាសាលាស្តីពី ការវិវត្តនៃសេចក្តីព្រាងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលគ្រឿងស្រវឹង ។

**៥.កិច្ចសហប្រតិបត្តិការអន្តរជាតិ**

-ឯកឧត្តម **ម៉ុង ឫទ្ធី** បានអញ្ជើញដឹកនាំគណៈប្រតិភូធុរកិច្ចកម្ពុជាសភាពាណិជ្ជកម្ម និងក្រុមហ៊ុនដែលមានជំនាញខាងកសិកម្ម សរុបចំនួន១៣ក្រុមហ៊ុន ទៅចូលរួមទស្សនាពិធីតាំងពិព័រណ៍ពាណិជ្ជកម្ម ស្តីពីកសិកម្ម កសិឧស្សាហកម្ម និងគ្រឿងចក្រ នៅសហរដ្ឋអាមេរិក។

-លោកជំទាវ **មាន សំអាន**, ឯកឧត្តម **យ៉ង់ សែម** និងឯកឧត្តម **ឈិត គីមយាត** បានអញ្ជើញចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន (AIPA) លើកទី៣៩ នៅប្រទេសឡាវ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែ តុលា ឆ្នាំ២០១៨

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

**ទេព ងន**

ចម្លងជូនៈ
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ